# ប្រស្នាពាក្យថា “ខុស”

**បទកាកគតិ**

បានឮគេថា នៅលើលោកា មានស្រីមានប្រុស
មានល្អអាក្រក់ មានត្រូវមានខុស មានឡើងមានចុះ
មានសើចមានយំ ។

ឮគេថាទៀត មានជួបមានឃ្លាត មានភ្លឺស្រទំ
មានខ្ពស់មានទាប មានតូចមានធំ មានរីកត្រសុំ
មានរោយអសារ ។

ពេលឃើញភ្នែកជាក់ មនុស្សម្នាក់ៗ សុទ្ធល្អអស្ចារ្យ
គ្រប់កាយគ្រប់ប្រាណ ពេលបានចរចា លើកតែទោសា
នៃអ្នកឯទៀត ។

រី ”ខ្ញុំ” នេះឯង បរិសុទ្ធមិនលែង ត្រូវគ្រប់នៀ្លត
អ្នកនេះធ្វើខុស អ្នកនោះធ្វើឃ្លាត អ្នកនុ៎ះមួយទៀត
ធ្វើមិនត្រឹមត្រូវ ។

មួយថាមួយភ្លើ មួយថាមួយស្មើរ រអ៊ូរង៉ូវ
មួយថាមួយឆោត ច្រឡោតខុសផ្លូវ បាយកើតពីស្រូវ
ដុះចេញពីដី ។

មួយគេមិនល្អ មួយមិនបវរ មួយមិនប្រពៃ
មួយគេអាក្រក់ មួយគេអប្រិយ ឯ ”ខ្ញុំ” នេះណី
ប្រសើរពេកក្ពាត់ ។

គិតៗចង់សើច នឹងផ្ទុះសំណើច ខ្លាចផ្អើលសព្វសត្វ
ខ្ញុំសុទ្ធតែត្រូវ គេខុសគ្រប់ម៉ាត់ មនុស្សលោកច្រវាត់
នរណាខុសពិត?

Ca. ០៧ ឧសភា ២០០៦

ភិក្ខុ ស្វាត សាលឿម